# របាយការណ៍ប្រចាំខែសីហា ឆ្នាំ ២០១៥ របស់មន្ទីរអភិវឌ្ឍន៍ជនបទ ខេត្តឧត្តរមានជ័យ

## ១. សេចក្តីផ្តើម

ខេត្តឧត្តរមានជ័យស្ថិតនៅទិសឧត្តរនៃព្រះរាជាណាចក្រកម្ពុជា មានចម្ងាយប្រមាណ ៤៤១ គីឡូម៉ែត្រ ពីរាជធានីភ្នំពេញ មានផ្ទៃដីសរុបចំនួន ៦.៦៣១,៧២ គីឡូម៉ែត្រក្រឡា។ ខេត្តនេះមានព្រំប្រទល់ខាងកើតជាប់នឹងខេត្តព្រះវិហារ ខាងលិចជាប់នឹង ខេត្តបន្ទាយមានជ័យ ខាងត្បូងជាប់នឹងខេត្តសៀមរាប និងខាងជើងប្រវែង ២២៥ គីឡូម៉ែត្រជាប់នឹងខេត្តស៊ីសាកេត ខេត្តបុរីរ៉ាំ និងខេត្តសុរិន្ទ្រ ប្រទេសថៃ និងមានស្រុកចំនួន ០៤ និងក្រុង ១ គឺស្រុកអន្លង់វែង ស្រុកត្រពាំងប្រាសាទ ស្រុកចុងកាល់ ស្រុកបន្ទាយអំពិល និងក្រុងសំរោង។

## ២. ស្ថានភាពរបស់មន្ទីរ

### ២.១ ការងាររដ្ឋបាល និងបុគ្គលិក

មន្ទីរអភិវឌ្ឍន៍ជនបទខេត្តឧត្តរមានជ័យ ដឹកនាំដោយប្រធានមន្ទីរ ០១ រូប និងអមដោយអនុប្រធានមន្ទីរចំនួន ០២ រូប និងមានបុគ្គលិកសរុបចំនួន ៣២ នាក់ ក្នុងនោះនៅកម្រិតរដ្ឋបាលថ្នាក់មន្ទីរមានការិយាល័យជំនាញចំនួន ០៨ និងថ្នាក់ស្រុក ០៥។

### ២.២ កិច្ចប្រជុំផ្សេងៗ និងទំនាក់ទំនងសាធារណៈ

- ថ្ងៃទី ២៦ ខែកក្កដា ថ្នាក់ដឹកនាំមន្ទីរបានចូលរួមពិធីវេរទានវស្សាប្រគេនព្រះសង្ឃគង់ចាំព្រះវស្សា ក្រោមអធិបតីភាព ឯកឧត្តម នាយឧត្តមសេនី **គង់ គឹម** អគ្គមេបញ្ជាការរង និងជានាយសេនាធិការចំរុះនៃកងយោធពលខេមរភូមិន្ទ និងជាប្រធានក្រុមការងារថ្នាក់ជាតិចុះជួយខេត្តឧត្តរមានជ័យ នៅវត្តប្រាសាទរាជាសំរោង
- ថ្ងៃទី ២៧ ខែកក្កដា មន្ត្រីចំនួន ០១ រូប បានចូលរួមពិធីបំពាក់គ្រឿងឥស្សរិយយសការងារ ជូនបុគ្គលិកអប់រំ នៅសាលប្រជុំធំសាលាខេត្តឧត្តរមានជ័យ
- ថ្ងៃទី ២៩ ខែកក្កដា ថ្នាក់ដឹកនាំមន្ទីរ បានចូលរួមកិច្ចប្រជុំបូកសរុបលទ្ធផលប្រចាំខែកក្កដា របស់គណៈកម្មាធិការពិគ្រោះយោបល់ស្ត្រី និងកុមារ នៅសាលប្រជុំសាលាខេត្តឧត្តរមានជ័យ
- ថ្ងៃទី ៣០ ខែកក្កដា ថ្នាក់ដឹកនាំមន្ទីរ បានចូលរួមពិធីប្រកាសក្រុមការងារទទួលខុសត្រូវដឹកនាំជំរុញផ្តល់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ នៅសាលប្រជុំមន្ទីរទំនាក់ទំនងរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច
- ថ្ងៃទី ០៤ ខែសីហា មន្ត្រីចំនួន ០១ រូប បានចូលរួមប្រជុំបូកសរុបលទ្ធផលការងារចុះវាស់វែងដីជូនប្រជាពលរដ្ឋ នៅចំណុចអូរអំបិល ភូមិតាម៉េង ឃុំអន្លង់វែង នៅសាលប្រជុំលេខ ១២ សាលាខេត្តឧត្តរមានជ័យ
- ថ្ងៃទី ០៤ ខែសីហា លោកប្រធានមន្ទីរបានជួបពិសារបាយសាមគ្គីជាមួយអភិបាលខេត្តបុរីរ៉ាំ នៃព្រះរាជាណាចក្រថៃ នៅច្រកទ្វារអន្តរជាតិជប់គគីរ
- ថ្ងៃទី ០៦ ខែសីហា លោកប្រធានមន្ទីរបានចូលរួមកិច្ចប្រជុំសាមញ្ញលើកទី ១៥ របស់ក្រុមប្រឹក្សាខេត្ត

ឆ្នាំទី ២ អាណត្តិទី ២ នៅសាលប្រជុំធំសាលាខេត្ត

- ថ្ងៃទី ០៧ ខែសីហា មន្ត្រីចំនួន ០១ រូប បានចូលរួមប្រជុំក្រុមបច្ចេកទេសចម្រុះវិស័យអប់រំថ្នាក់ក្រោមជាតិ នៅមន្ទីរអប់រំយុវជន និងកីឡា ខេត្តឧត្តរមានជ័យ
- ថ្ងៃទី ១៥ ខែសីហា ថ្នាក់ដឹកនាំមន្ទីរបានចូលរួមពិធីផ្សព្វផ្សាយអំពីតួនាទី ភារកិច្ចរបស់ក្រុមប្រឹក្សាសកម្មភាពជនពិការ ខេត្តឧត្តរមានជ័យ នៅសាលប្រជុំសាលាខេត្ត
- ថ្ងៃទី ១៨ ខែសីហា លោកប្រធានមន្ទីរបានចូលរួមក្នុងពិធីបញ្ចុះបឋមសិលាសាងសង់អាគារសិក្សាសាលាបឋមសិក្សាដងទង់នៅក្នុងសាលាបឋមសិក្សាដងទង់ ភូមិដងទង់ សង្កាត់កូនក្រៀល ក្រុងសំរោង
- ថ្ងៃទី ១៩ ខែសីហា លោកប្រធានមន្ទីរបានចូលរួមពិធីបញ្ចុះបឋមសិលាសាងសង់សាលាធម្មសភាថ្មី នៅវត្តប្រាសាទរាជាសំរោង និង
- ថ្ងៃទី ២០ ខែសីហា មន្ត្រីចំនួន ០១ រូប ចូលរួមសិក្ខាសាលាពិនិត្យ និងពិភាក្សាលើសេចក្តីព្រាងផែនការយុទ្ធសាស្ត្រ ០៥ ឆ្នាំ ស្តីពីការអភិវឌ្ឍធនធានមនុស្ស របស់ក្រសួងអភិវឌ្ឍន៍ជនបទ នៅទីស្តីការក្រសួងអភិវឌ្ឍន៍ជនបទ។

## ៣. លទ្ធផលសម្រេចបានតាមវិស័យ

### ៣.១ ការងារផ្លូវជនបទ

- ចុះសិក្សាខ្សែផ្លូវអាទិភាពសម្រាប់ដាក់បញ្ចូលក្នុងផែនការជួសជុលបន្ទាន់បានចំនួន ១៥ គម្រោង ស្មើនឹង ៣១.៧១៨ គ.ម នៅស្រុកចុងកាល់
- បានជួសជុលផ្លូវបន្ទាន់ក្រាលក្រួសក្រហមប្រវែង ១.៥២០ ម៉ែត្រ នៅភូមិបន្ទាយថ្មី ឃុំចុងកាល់ ស្រុកចុងកាល់ ជាលទ្ធផល សម្រេចបាន ១០០% អនុវត្តដោយនាយកដ្ឋានផ្លូវលំជនបទ និង
- បានចុះធ្វើបច្ចុប្បន្នភាព និងប្រមូលទិន្នន័យផ្លូវជនបទក្នុងស្រុក/ក្រុងចំនួន ០២ គឺក្រុងសំរោង និងស្រុកចុងកាល់ សរុបបានប្រវែង ៤០ គ.ម ។

### ៣.២ ការងារផ្គត់ផ្គង់ទឹកស្អាតជនបទ

- បានសាងសង់អណ្តូងស្នប់អាហ្វ្រីដេវចំនួន ០៤ កន្លែង (គ្មានទឹក ០១ កន្លែង) នៅភូមិតេជោថ្នល់កែង ឃុំត្រពាំងប្រាសាទ ស្រុកត្រពាំងប្រាសាទ
- បានសាងសង់អណ្តូងស្នប់អាហ្វ្រីដេវចំនួន ០២ កន្លែង នៅភូមិតេជោដីក្រហម ឃុំត្រពាំងប្រាសាទ ស្រុកត្រពាំងប្រាសាទ
- បានជួសជុលអណ្តូងស្នប់អាហ្វ្រីដេវខូចចំនួន ០៣ អណ្តូង ភូមិឈើក្រំ សង្កាត់កូនក្រៀល ក្រុងសំរោង
- បានជួសជុលអណ្តូងស្នប់អាហ្វ្រីដេវខូចចំនួន ០២អណ្តូង ភូមិចំប៉ាសុខ សង្កាត់កូនក្រៀល ក្រុងសំរោង
- បានជួសជុលអណ្តូងស្នប់លេខ ៦ ខូច ចំនួន ០១ អណ្តូង ភូមិគោកចំបក់ សង្កាត់សំរោង ក្រុងសំរោង
- បានជួសជុលអណ្តូងស្នប់លេខ ៦ ខូច ចំនួន ០១ អណ្តូង ភូមិកណ្តោក សង្កាត់សំរោង ក្រុងសំរោង
- បានជួសជុលអណ្តូងស្នប់លេខ ៦ ខូច ចំនួន ០១ អណ្តូង ភូមិគោកគ សង្កាត់សំរោង ក្រុងសំរោង

- បានជួសជុលអណ្ដូងស្នប់លេខ ៦ រួច ចំនួន ០២ អណ្ដូង ភូមិឈើក្រំ សង្កាត់កួនក្រៀល ក្រុងសំរោង
- បានជួសជុលអណ្ដូងស្នប់លេខ ៦ រួច ចំនួន ០២ អណ្ដូង ភូមិត្រពាំងស្លែង សង្កាត់កួនក្រៀល ក្រុងសំរោង និង
- បានជួសជុលអណ្ដូងស្នប់លេខ ៦រួច ចំនួន ០២អណ្ដូង ភូមិអន្លង់វែង សង្កាត់កួនក្រៀល ក្រុងសំរោង។

### ៣.៣ ការងារផែនាំសុខភាពជនបទ

- ចុះសម្របសម្រួលបើកកិច្ចប្រជុំប្រចាំត្រីមាសថ្នាក់ឃុំស្ដីពីកម្មវិធីទឹកស្អាត និងអនាម័យ នៅតាមឃុំគោលដៅចំនួន ០៥ ឃុំ មកពី ៤៣ ភូមិ ៣០ សាលា នៅក្នុងស្រុកចុងកាល់ និងក្រុងសំរោង មានអ្នកចូលរួមសរុបចំនួន ១៣៧ នាក់ ស្រី ១៨ នាក់
- រៀបចំកម្មវិធីអប់រំផ្សព្វផ្សាយការលើកកម្ពស់អនាម័យតាមរយៈវិទ្យុក្នុងកម្មវិធីសំនួរ-ចម្លើយដើម្បីសំណូមពរបទចម្រៀង ចំនួន ២៩ ម៉ោង **(១៩-កក្កដា ដល់ ១៦-សីហា ឆ្នាំ២០១៥)** នៅស្ថានីយ៍វិទ្យុជាតិប្រាសាទតាមាន់ **FM 90.00 MHz** ដោយមានប្រិយ៍មិត្តទូរស័ព្ទចូលសរុបចំនួន ១៧០ នាក់ ស្រី ៨៥ នាក់ (ភាគច្រើនជាយុវវ័យ) និង
- បានសម្របសម្រួលរៀបចំកិច្ចប្រជុំមួយស្ដីពី ការងារទឹកស្អាត និងអនាម័យ ជាមួយអង្គការដៃគូ និងស្ថាប័នពាក់ព័ន្ធ នៅសាលប្រជុំមន្ទីរអភិវឌ្ឍន៍ជនបទខេត្ត សមាសភាពចូលរួមសរុបចំនួន ២៥ នាក់ ស្ត្រី ០១នាក់ ។

### ៣.៤ ការអភិវឌ្ឍន៍ព្រំដែនទិសខាងជើង និងខាងលិចប្រទេស

#### ៣.៤.១ ការងារសាងសង់ផ្ទះ

ភូមិតាមាន់សែនជ័យ÷ ផ្ទះចំនួន ៣៧ ខ្នង បានបញ្ចប់រួចរាល់ ១០០%។

#### ៣.៤.២ ការងារសាងសង់ផ្លូវ (អនុវត្តដោយនាយកដ្ឋានផ្លូវលំជនបទ)

- ភូមិតាមាន់សែនជ័យ÷ ផ្លូវក្រាលក្រួសក្រហម ០១ ខ្សែ មាន ០៥ កំណាត់ ប្រវែង ៨.៤០០ ម៉ែត្រ ទទឹង ០៥ ម៉ែត្រ សំណង់សិល្បការគ្រប់ប្រភេទ ២៧ កន្លែង ចាក់ដីស ៩០% សាងសង់លូប្រអប់បាន ៦០% និងលូមូលបាន ៧៥% សម្រេចបានលទ្ធផល ៩០%
- ភូមិប្រាសាទក្រហមសែនជ័យ÷ ផ្លូវក្រាលក្រួសក្រហមមាន ០៧ កំណាត់ ប្រវែងសរុប ១២.០០០ ម៉ែត្រ ទទឹង ៥ ម៉ែត្រ (ផ្លូវមេប្រវែង ៤.៥០០ ម៉ែត្រ ) និងលូមូលចំនួន ២០ កន្លែង សម្រេចបានលទ្ធផល ១០០% និង
- ភូមិពពេលសែនជ័យ÷ ផ្លូវក្រាលក្រួសក្រហម ០១ ខ្សែ ប្រវែង ៣.៦០០ ម៉ែត្រ ចាក់ដីសបាន ១០០% ក្រាលក្រួសក្រហមបាន ៩០% សាងសង់សំណង់សិល្បការបាន ៥០%។

### ៣.៥ ការិយាល័យស្រុក/ក្រុង

- ប្រធានការិយាល័យក្រុងសំរោង ចូលរួម គ.ក.ស.ក ប្រចាំខែកក្កដា ឆ្នាំ២០១៥ និងប្រជុំសាមញ្ញលើកទី ១៤ របស់ក្រុមប្រឹក្សាក្រុង នៅសាលាក្រុងសំរោង

- ប្រធានការិយាល័យស្រុកចុងកាល់ ចូលរួមប្រជុំគណៈកម្មការទទួលបន្ទុកស្ត្រី និងកុមារ និងប្រជុំសាមញ្ញលើកទី ១៤ របស់ក្រុមប្រឹក្សាស្រុក ដែលមានសមាសភាពចូលរួម ៣១ នាក់ ស្រី ០៧ នាក់
- ប្រធានការិយាល័យស្រុកបន្ទាយអំពិល ចូលរួមកាកបាទក្រហមចែកអំណោយជូនប្រជាពលរដ្ឋចំនួន ០៤ ឃុំ នៅស្រុកបន្ទាយអំពិល ខេត្តឧត្តរមានជ័យ និង
- ប្រធានការិយាល័យស្រុកបន្ទាយអំពិល ចូលរួមប្រជុំការងារយេនឌ័រថ្នាក់ស្រុក នៅសាលាស្រុកបន្ទាយអំពិល។

## ៤. ទិសដៅការងារបន្ត

- ជួសជុលផ្លូវបន្ទាន់ចាប់ពីភូមិពង្រដល់ភូមិព្រៃនគរ ប្រវែង ៣.៣០០ ម៉ែត្រ
- ចុះធ្វើបច្ចុប្បន្នភាព និងប្រមូលទិន្នន័យផ្លូវជនបទបន្តនៅក្រុងសំរោង និងស្រុកអន្លង់វែង
- ចូលរួមរៀបចំកិច្ចប្រជុំប្រចាំត្រីមាស ស្តីពីកម្មវិធីទឹកស្អាត និងអនាម័យជនបទ ជាមួយអង្គការដៃគូរ និងស្ថាប័នពាក់ព័ន្ធ
- បន្តរៀបចំកម្មវិធីអប់រំផ្សព្វផ្សាយការលើកកម្ពស់អនាម័យ នៅជនបទ តាមរយៈវិទ្យុ និង
- សាងសង់ស្រះសហគមន៍ ០១ កន្លែង ទំហំ(៤០ ម X ៣០ ម X ៣ ម ) ភូមិតាមាន់សែនជ័យ។